**វាក្យសព្ទច្បាប់ទី២**
**រូបវន្តបុគ្គល**

**ក.** រូបវន្តបុគ្គល ជាភាសាបរទេសភាសាអង់គ្លេស (Natural Person) ជាភាសាបារាំង (Personne Physique)។

**ខ**. ច្បាប់ខ្លះចែងផ្តល់ន័យថា "បុគ្គល"សំដៅដល់នីតិបុគ្គលនិងរូបវន្តបុគ្គល (ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាសអាវុធមហាប្រល័យ ច្បាប់ស្តីពីវិនិយោគ ច្បាប់ស្តីពីការបោះផ្សាយនិងជួញដូរមូលបត្រមហាជន ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ និងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក)។

**គ**.ខ្លឹមសារដកស្រង់៖

**១**. រូបវន្តបុគ្គល ៖ បុគ្គលដែលមានរូបមែនៗ គឺមនុស្សមែនៗ ផ្ទុយនឹងនីតិបុគ្គលដែលជាមនុស្សដោយសន្មតតាមរបៀបច្បាប់ (ច្បាប់ភូមិបាលឆ្នាំ២០០១)។

**កំណត់សំគាល់៖** ច្បាប់បានចែងញែករវាងពាក្យ "ជន" និង "បុគ្គល"។ "ជន" សំដៅលើរូបវន្តបុគ្គល រីឯពាក្យ"បុគ្គល" សំដៅទាំង រូបវន្តបុគ្គល និងនីតិបុគ្គល(ដូចខាងលើ)។ ជាក់ស្តែងមាត្រា៣១នៃក្រមព្រហ្មទណ្ឌប្រើពាក្យ "ជនណា..."។ ជាទូទៅ រូបវន្តបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ទោះបីច្បាប់មិនចែងចំថារូបវន្តបុគ្គល...ក៏ប៉ុន្តែ ការដាក់នីតិបុគ្គលឲ្យទទួលខុសត្រូវព្រហ្មទណ្ឌបាន លុះត្រាមាន ច្បាប់ចែងកំណត់ដាក់លាក់ (មាត្រា៤២នៃក្រមព្រហ្មទណ្ឌឆ្នាំ២០១០)។